**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ៣៥..ស.សរ....

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវអគាររដ្ឋបាលខេត្ត និងហេដ្ឋារចនាសម្ព័ន្ធនៃទីរួមខេត្តត្បូងឃ្មុំ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតខេត្តត្បូងឃ្មុំ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ ៤១ សសរ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំរដ្ឋបាលខេត្តត្បូងឃ្មុំ
- បានឃើញសេចក្តីសម្រេចលេខ ៦០ សសរ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបន្ថែមសមាសភាពក្នុងគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំរដ្ឋបាលខេត្តត្បូងឃ្មុំ
- យោងតាមការចាំបាច់



www.pheakdeylaw.com

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវអគាររដ្ឋបាលខេត្ត និងហេដ្ឋារចនាសម្ព័ន្ធនៃទីរួមខេត្តត្បូងឃ្មុំ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២. ឯកឧត្តម **ឈិន កេតនា** | អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការគណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ | អនុប្រធាន |
| ៣. ឯកឧត្តម **ប្រាក់ សំអឿន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល | អនុប្រធាន |
| ៤. ឯកឧត្តម **ឡាន់ ឆន** | ប្រធានក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ | អនុប្រធាន |
| ៥. ឯកឧត្តម **ប្រាជ្ញ ចន្ទ** | អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ | អនុប្រធានអចិន្ត្រៃយ៍ |
| ៦. តំណាងខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី | | អនុប្រធាន |
| ៧. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| ៨. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៩. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ១០. តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | | សមាជិក |
| ១១. តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | | សមាជិក |
| ១២. តំណាងក្រសួងធនធានទឹក និងឧតុនិយម | | សមាជិក |
| ១៣. តំណាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| ១៤. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឌូច ណារ៉ុថ** | អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានអង្គរក្ស | សមាជិក |
| ១៥. ឯកឧត្តម ឧត្តមសេនីយ៍ឯក **អ៊ុខ សារិទ្ធ** | មេបញ្ជាការរង និងជានាយសេនាធិការបញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ១៦. ឯកឧត្តម **សួស ប្រាថ្នា** | អគ្គនាយករងទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត | សមាជិក |
| ១៧. ឯកឧត្តម **សេខ យូអ៊ាន់** | អគ្គនាយករង និងជាប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(ផ្នែករដ្ឋបាលទូទៅ) | សមាជិក |
| ១៨. តំណាងអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ | | សមាជិក |
| ១៩. លោកនាយកក្រុមហ៊ុន លី ឈួង សំណង់ និងអាហារ័ណ នីហារ័ណ | | សមាជិក |



www.pheakdeylaw.com

**ប្រការ ២.-**

គណៈកម្មការនេះមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងរៀបចំពិធីសម្ពោធឲ្យដំណើរការបានល្អប្រសើរ
- ក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅទីកន្លែងប្រារព្ធពិធី
- រៀបចំវេទិកា និងទីកន្លែងប្រារព្ធពិធីឲ្យបានសមស្រប
- រៀបចំកម្មវិធី និងអញ្ជើញប្រជាពលរដ្ឋ និងសមាសភាពគណៈប្រតិភូអមដំណើរចូលរួមក្នុងពិធីសម្ពោធ តាមកាលបរិច្ឆេទកំណត់
- ចាត់ចែងការងារពិធីការសម្រាប់ពិធីសម្ពោធ និងរៀបចំបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំជាន់ខ្ពស់
- ត្រួតពិនិត្យមើលស្ថានភាពនៅខាងក្នុង និងខាងក្រៅអគាររដ្ឋបាលខេត្តត្បូងឃ្មុំ និងហេដ្ឋារចនាសម្ព័ន្ធនៃទីរួមខេត្តត្បូងឃ្មុំ ព្រមទាំងការបំពាក់ឧបករណ៍ បរិក្ខារ និងសម្ភារផ្សេងៗ មុនពិធីសម្ពោធ
- ចាត់តាំងគ្រូពេទ្យ ថ្នាំពេទ្យ និងរថយន្តសង្គ្រោះសម្រាប់សង្គ្រោះបន្ទាន់
- លើកគម្រោងថវិកាដែលត្រូវចំណាយសម្រាប់បម្រើការរៀបចំពិធីសម្ពោធ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ៣.-**

ក្នុងការអនុវត្តការងារ ប្រធានគណៈកម្មការត្រូវរាយការណ៍ និងសុំយោបល់ដឹកនាំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំរដ្ឋបាលខេត្តត្បូងឃ្មុំ។

អនុប្រធាន និងសមាជិកគណៈកម្មការ ត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានគណៈកម្មការ។

**ប្រការ ៤.-**

គណៈកម្មការអាចមានអនុគណៈកម្មការមួយចំនួនជាជំនួយការ ដែលកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

គណៈកម្មការមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួន ដើម្បីជួយការងារតាមតម្រូវការចាំបាច់។

**ប្រការ ៥.-**

គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ ៦.-**

ការចំណាយផ្សេងៗបម្រើឲ្យការរៀបចំពិធីសម្ពោធនេះ ត្រូវប្រើប្រាស់ថវិការបស់រដ្ឋបាលខេត្តត្បូងឃ្មុំ។

**ប្រការ ៧.-**

គណៈកម្មការនេះត្រូវបញ្ចប់ការងាររបស់ខ្លួននៅពេលដែលពិធីសម្ពោធបានចប់សព្វគ្រប់ជាស្ថាពរ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។



ស

www.pheakdeylaw.com

**ប្រការ ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ គណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៩
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ



៥

www.pheakdeylaw.com